ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

Ministry of Commerce

No. ៦៧២ MOC / SM 2012

# ប្រកាស

## ស្តីពី

## ការបង្កើតក្រុមប្រឹក្សាប្រឡង គណៈកម្មការប្រឡង សម្រាប់រៀបចំការប្រឡងជ្រើសរើសភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រម លេខ នស/រកម/០២០២/០០៦ ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- បានឃើញអនុក្រឹត្យ លេខ ៩១ អនក្រ.បក ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យ លេខ ៦៤ អនក្រ.បក ចុះថ្ងៃទី ១២ ខែកក្កដា ឆ្នាំ២០០៦ ស្តីពីការអនុវត្តច្បាប់ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- យោងប្រកាសលេខ ០៤៥ MOC / SM 2011 ចុះថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ២០១១ របស់ក្រសួងពាណិជ្ជកម្ម ស្តីពីភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាកក្នុងព្រះរាជាណាចក្រកម្ពុជា
- យោងតាមការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម

## សម្រេច

**ប្រការ ១.** បង្កើតក្រុមប្រឹក្សាប្រឡងជ្រើសរើសភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាកក្នុងព្រះរាជាណាចក្រកម្ពុជា សម្រាប់អាណត្តិ ៣ (បី)ឆ្នាំ ដំបូង ដែលមានសមាសភាពដូចខាងក្រោម ៖

| | | | | |
|---|---|---|---|---|
| ១.ឯកឧត្តម | វ៉ា | វុតសាន | ប្រធាននាយកដ្ឋានកម្មសិទ្ធិបញ្ញា | ប្រធាន |
| ២.លោក | អ៊ុំ | សុថា | ប្រធាននាយកដ្ឋានបុគ្គលិក | អនុប្រធាន |
| ៣.លោក | ស៊ឹម | សុខខេង | អនុប្រធាននាយកដ្ឋានកម្មសិទ្ធិបញ្ញា | សមាជិកអចិន្ត្រៃយ៍ |
| ៤.លោក | អប់ | វ៉ាឌី | អនុប្រធាននាយកដ្ឋានកម្មសិទ្ធិបញ្ញា | សមាជិក |
| ៥.លោក | ង៉ោ | ធូ | អនុប្រធាននាយកដ្ឋានបុគ្គលិក | សមាជិក |
| ៦.លោក | ហេង | សំបូរ | អនុប្រធានការិយាល័យនៃនាយកដ្ឋានកម្មសិទ្ធិបញ្ញា | សមាជិក |
| ៧.លោក | ខេង | បូរី | អនុប្រធានការិយាល័យនៃនាយកដ្ឋានបុគ្គលិក | សមាជិក |



ក្រសួងពាណិជ្ជកម្ម
លេខ ១៩-៦១ ផ្លូវក្រសួងពាណិជ្ជកម្ម (ផ្លូវ១១៣បេ)
ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៨៦៦ ០៨៨/៨៦៦ ៤៧៨
ទូរសារលេខ: (៨៥៥) ២៣ ៨៦៦ ៤២៥
អ៊ីម៉ែល: moccab@moc.gov.kh

**ប្រការ ២.** បង្កើតគណៈកម្មការប្រឡង ជ្រើសរើសភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាកក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីធ្វើជាសេនាធិការឲ្យក្រុមប្រឹក្សាប្រឡង សម្រាប់អាណត្តិដំបូងនេះ ដែលមានសមាសភាពដូចខាងក្រោម ៖

| | | | | |
|---|---|---|---|---|
| ១.លោក | ស៊ឹម | សុខខេង | អនុប្រធាននាយកដ្ឋានកម្មសិទ្ធិបញ្ញា | ប្រធាន |
| ២.លោក | ង៉ោ | ធូ | អនុប្រធាននាយកដ្ឋានបុគ្គលិក | អនុប្រធាន |
| ៣.លោក | គឹម | ធនសំណាង | អនុប្រធានការិ.នៃនាយកដ្ឋានកម្មសិទ្ធិបញ្ញា | លេខាធិការ |
| ៤.លោកស្រី | ឡាយ | ចាន់ធឿន | អនុប្រធានការិ.នៃនាយកដ្ឋានបុគ្គលិក | សមាជិក |
| ៥.លោក | លី | ឡាមី | អនុប្រធានការិ.នៃនាយកដ្ឋានកម្មសិទ្ធិបញ្ញា | សមាជិក |

**ប្រការ ៣.** ក្រុមប្រឹក្សាប្រឡង និងគណៈកម្មការប្រឡង ត្រូវបំពេញមុខងាររបស់ខ្លួន ដោយស្មារតីទទួលខុសត្រូវខ្ពស់ ក្នុងការរៀបចំប្រឡងជ្រើសរើសភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក ឲ្យបានសមស្របតាមនីតិវិធីជាធរមាន ធានាបាននូវប្រសិទ្ធភាព តម្លាភាព និងមានកាតព្វកិច្ចអនុវត្តឲ្យបានត្រឹមត្រូវនូវសិទ្ធិអំណាច ភារកិច្ចរបស់ខ្លួន ដូចមានចែងក្នុងប្រការ៧ ប្រការ៨ និងប្រការ១១ នៃប្រកាសលេខ ០៩៥ MOC / SM 2011 ចុះថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ២០១១ របស់ក្រសួងពាណិជ្ជកម្ម ស្តីពីភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាកក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ៥.** ក្រុមប្រឹក្សាប្រឡងមានសិទ្ធិបង្កើតលេខាធិការដ្ឋានប្រឡង ដែលមានទីចាត់ការនៅក្នុងនាយកដ្ឋានកម្មសិទ្ធិបញ្ញា និងអាចចាត់តាំងមន្ត្រីមួយចំនួនជាជំនួយការ តាមការចាំបាច់។

**ប្រការ ៦.** នាយិកាខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋានកម្មសិទ្ធិបញ្ញា ប្រធាននាយកដ្ឋានបុគ្គលិក គ្រប់អង្គភាពពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១២

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម ប្រសិទ្ធ**

**កន្លែងទទួល ៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួង ស្ថាប័នពាក់ព័ន្ធ
-រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
-អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល
-ដូចប្រការ៦
-ឯកសារ-កាលប្បវត្តិ



**ក្រសួងពាណិជ្ជកម្ម**
លេខ ១៩-៦១ ផ្លូវក្រសួងពាណិជ្ជកម្ម (ផ្លូវ១១៣បេ)
ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៨៦៦ ០៨៨/៨៦៦ ៨៧៨
ទូរសារលេខ: (៨៥៥) ២៣ ៨៦៦ ៨២៥
អ៊ីម៉ែល: moccab@moc.gov.kh

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**
**នាយកដ្ឋានកម្មសិទ្ធិបញ្ញា**
**និងនាយកដ្ឋានបុគ្គលិក**

# កំណត់បង្ហាញ

**ខ្លឹមសារសង្ខេប ៖** ការរៀបចំប្រកាសស្ដីពីការបង្កើត ក្រុមប្រឹក្សា និងគណៈកម្មការប្រឡងជ្រើសរើសភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាកក្នុងព្រះរាជាណាចក្រកម្ពុជា។

| **យោបល់អន្តរនាយកដ្ឋានកម្មសិទ្ធិបញ្ញា និងនាយកដ្ឋានបុគ្គលិក** | **មតិសម្រេចរបស់ ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម** |
|---|---|
| **គោរពជូន**<br>**ឯ.ឧ អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ**<br>**និងឯ.ឧ អគ្គនាយកពាណិជ្ជកម្មក្នុងប្រទេស**<br><br>ដើម្បីចាត់តាំងអនុវត្តឲ្យបានត្រឹមត្រូវតាមប្រកាស លេខ ០៤៥ MOC / SM2011 ចុះថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ២០១១ របស់ក្រសួងពាណិជ្ជកម្ម ស្ដីពីភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាកក្នុងព្រះរាជាណាចក្រកម្ពុជា ពិសេស ខ្លឹមសារនៃប្រការ៥ រហូតដល់ប្រការ ១៣ នៃប្រកាសនេះ និងក្នុងគោលដៅពង្រឹងប្រសិទ្ធភាព នៃការអនុវត្តនីតិវិធីច្បាប់ដែលទាក់ទងនឹងវិស័យកម្មសិទ្ធិបញ្ញា<br><br>នាយកដ្ឋានកម្មសិទ្ធិបញ្ញា រួមសហការជាមួយនាយកដ្ឋានបុគ្គលិក បានរៀបចំជា *ប្រកាស ស្ដីពីការការបង្កើតក្រុមប្រឹក្សាប្រឡងគណៈកម្មការប្រឡង សម្រាប់រៀបចំការប្រឡងជ្រើសរើសភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក* ដូចមានខ្លឹមសារនៃសេចក្ដីព្រាង ចំនួន ០១ច្បាប់ គោរពជូនភ្ជាប់ជាមួយនេះ។<br><br>គោរពជូន ឯកឧត្តម មេត្តាជ្រាប និងពិនិត្យ ដើម្បីស្នើសុំការសម្រេចដ៏ខ្ពង់ខ្ពស់ពី ឯកឧត្តមទេសរដ្ឋមន្ត្រី។<br><br>រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ តុលា ឆ្នាំ២០១២<br>ប្រធាននាយកដ្ឋានកម្មសិទ្ធិបញ្ញា ប្រធាននាយកដ្ឋានបុគ្គលិក | [illegible]<br>10/10/12 |
| **យោបល់ឯ.ឧ អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ** | |
| [illegible]<br>8 តុលា 2012 | |

4513
Oct 8/12